**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ២៤៦ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ហត្ថលេខាឌីជីថល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងនិងជំរុញការប្រើប្រាស់ហត្ថលេខាឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពខ្ពស់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី៖

- គោលការណ៍នៃហត្ថលេខាឌីជីថលនិងស្ថាប័នមានសមត្ថកិច្ច
- ការផ្តល់ ការកែប្រែ ការព្យួរ ការបញ្ឈប់ និងការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល
- វិញ្ញាបនបត្រហត្ថលេខាឌីជីថល
- កាតព្វកិច្ចរបស់វិញ្ញាតធរហត្ថលេខាឌីជីថល
- កាតព្វកិច្ចរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការ ដែលពាក់ព័ន្ធនឹងហត្ថលេខាឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

ពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចខាងក្រោម៖

**កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល** សំដៅដល់បុគ្គលដែលទទួលបានវិញ្ញាបនបត្រហត្ថលេខាឌីជីថលពីវិញ្ញាតធរហត្ថលេខាឌីជីថល។

**គន្លឹះបង្កើតហត្ថលេខាឌីជីថល** សំដៅដល់កូដនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលត្រូវបានប្រើប្រាស់សម្រាប់បង្កើតហត្ថលេខាឌីជីថល។

**គន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថល** សំដៅដល់កូដនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលត្រូវបានប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃហត្ថលេខាឌីជីថល។

**ទិន្នន័យ** សំដៅដល់អត្ថបទ រូបភាព សំឡេង វីដេអូ ឬសញ្ញាណផ្សេងៗទៀតដែលត្រូវបានបង្កើត ប្រើប្រាស់ និងរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ប្រព័ន្ធកុំព្យូទ័រ** សំដៅដល់រាល់ឧបករណ៍អេឡិកត្រូនិកទាំងឡាយ ទោះស្ថិតនៅដាច់ដោយឡែកតែឯង ឬជាបណ្តុំនៃឧបករណ៍អេឡិកត្រូនិកដែលតភ្ជាប់គ្នា ឬឧបករណ៍ពាក់ព័ន្ធដែលដំណើរការប្រព្រឹត្តកម្មស្វ័យប្រវត្តិនៃទិន្នន័យ ក្នុងនោះរាប់ទាំងឧបករណ៍គ្រប់ប្រភេទដែលមានសមត្ថភាពធ្វើប្រព្រឹត្តកម្មទិន្នន័យ ដោយរាប់បញ្ចូលតែមិនកំណត់ត្រឹមកុំព្យូទ័រ កុំព្យូទ័របន្ទះ និងទូរស័ព្ទ។

**លិខិតលាយលក្ខណ៍អក្សរ** សំដៅដល់លិខិតដែលមានទម្រង់ជាក្រដាសដែលមានឬតម្រូវឱ្យមាន ហត្ថលេខាឬស្នាមម្រាមដៃ, ហត្ថលេខាឬស្នាមម្រាមដៃ និងឈ្មោះ, ហត្ថលេខាឬស្នាមម្រាមដៃ និងត្រា, ឈ្មោះនិងត្រា, ឬហត្ថលេខាឬស្នាមម្រាមដៃ ឈ្មោះ និងត្រា។

**វិញ្ញាបនបត្រហត្ថលេខាឌីជីថល** សំដៅដល់កំណត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រមួយដែលចេញដោយវិញ្ញាតធរហត្ថលេខាឌីជីថល សម្រាប់បញ្ជាក់អត្តសញ្ញាណរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ដែលជាម្ចាស់កម្មសិទ្ធិនៃគន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថល។

**វិញ្ញាតធរហត្ថលេខាឌីជីថល** សំដៅដល់នីតិបុគ្គលដែលធ្វើវិញ្ញាតកម្មហត្ថលេខាឌីជីថល។

**វិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់ការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**វិធានរួមស្តីពីវិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់វិធាននិងនីតិវិធីពាក់ព័ន្ធនឹងវិញ្ញាតកម្មហត្ថលេខាឌីជីថលរបស់វិញ្ញាតធរហត្ថលេខាឌីជីថល ដើម្បីធានាសុវត្ថិភាពនិងប្រសិទ្ធភាពនៃវិញ្ញាតកម្មហត្ថលេខាឌីជីថលនិងការប្រើប្រាស់ហត្ថលេខាឌីជីថលស្របទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធនឹងស្តង់ដានិងគោលការណ៍បច្ចេកទេស ដែលបានកំណត់ដោយ ក.ប.ទ.។

**សារអេឡិកត្រូនិក** សំដៅដល់ព័ត៌មានដែលត្រូវបានបង្កើតឡើង បញ្ជូន ទទួល ឬរក្សាទុកក្នុងទម្រង់ជាអេឡិកត្រូនិកនៅក្នុងប្រព័ន្ធកុំព្យូទ័រ។

**ហត្ថលេខាឌីជីថល** សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិកត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថលនិងផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិកត្រូនិក ដែលហត្ថលេខីឌីជីថលបានចុះហត្ថលេខា។

**ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ** សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធមួយដែលមានយន្តការនិងគ្រឿងសម្ភារៈបរិក្ខារបច្ចេកទេស បុគ្គលិក គោលនយោបាយ និងនីតិវិធីក្នុងការធានានូវសន្តិសុខនិងសុវត្ថិភាពសម្រាប់ការគ្រប់គ្រងនិងការប្រើប្រាស់ហត្ថលេខាឌីជីថល។

**អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល** សំដៅដល់អាជ្ញាបណ្ណដែលចេញដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីផ្តល់នីតិសម្បទាឱ្យនីតិបុគ្គលណាមួយជាវិញ្ញាតធរហត្ថលេខាឌីជីថល។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .—**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើហត្ថលេខាឌីជីថល និងផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់ក្រសួង ស្ថាប័ន និងអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**អ.ប.គ.ព.**) ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុងការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា៦ .—**

**ក.ប.ទ.** ត្រូវកំណត់ស្តង់ដានិងគោលការណ៍បច្ចេកទេសដើម្បីលើកកម្ពស់សុវត្ថិភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ហត្ថលេខាឌីជីថល ជាអាទិ៍៖

ក- ស្តង់ដានិងនិម្មាបនកម្មហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ

ខ- គោលការណ៍ណែនាំអំពីការស្ថាបនានិងការដំឡើងហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ និងការប្រើប្រាស់ហត្ថលេខាឌីជីថល។

**មាត្រា៧ .-**

**អ.ប.គ.ព.** ត្រូវបង្កើតនិងរក្សាបញ្ជីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ដោយចុះបញ្ជាក់នូវព័ត៌មានជាក់លាក់មួយចំនួន ជាអាទិ៍ អត្តសញ្ញាណនៃវិញ្ញាតធរហត្ថលេខាឌីជីថល កាលបរិច្ឆេទនៃអាជ្ញាបណ្ណ លក្ខខណ្ឌបច្ចេកទេសនៃហត្ថលេខាឌីជីថល និងការទទួលបានសិទ្ធិធ្វើអាជីវកម្ម ព្រមទាំងបញ្ជីឧបសម្ព័ន្ធ។

**មាត្រា៨ .-**

**អ.ប.គ.ព.** ត្រូវផ្សាយជាសាធារណៈនូវឈ្មោះវិញ្ញាតធរហត្ថលេខាឌីជីថលទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងឈ្មោះវិញ្ញាតធរហត្ថលេខាឌីជីថលបរទេសដែលត្រូវបានទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣
## គោលការណ៍នៃហត្ថលេខាឌីជីថល

**មាត្រា៩ .-**

ដើម្បីចាត់ទុកជាហត្ថលេខាឌីជីថលត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

ក- បញ្ជាក់អត្តសញ្ញាណរបស់ហត្ថលេខីឌីជីថលដោយត្រឹមត្រូវនិងជាក់លាក់

ខ- បញ្ជាក់អំពីស្ថានភាពដើមនៃសារអេឡិកត្រូនិក

គ- បញ្ជាក់អំពីពេលវេលានិងកាលបរិច្ឆេទនៃការចុះហត្ថលេខាឌីជីថល

ឃ- ចំណុចផ្សេងទៀតដែលកំណត់ដោយ **អ.ប.គ.**។

**មាត្រា១០ .-**

សារអេឡិកត្រូនិកដែលមានភ្ជាប់ហត្ថលេខាឌីជីថលបញ្ជាក់ដោយវិញ្ញាតធរហត្ថលេខាឌីជីថល មានតម្លៃគតិយុត្តស្មើនឹងលិខិតលាយលក្ខណ៍អក្សរ។

**មាត្រា១១ .-**

រាល់ប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធអនឡាញទាំងអស់ ត្រូវប្រើប្រាស់ហត្ថលេខាឌីជីថលស្របតាមអនុក្រឹត្យនេះ លើកលែងមានការកំណត់ផ្សេងដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងធនាគារជាតិនៃកម្ពុជា។

**មាត្រា១២ .-**

ត្រូវបានហាមឃាត់ដាច់ខាតចំពោះការផ្សព្វផ្សាយគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ។

ត្រូវបានហាមឃាត់ចំពោះការរក្សាទុកឬការប្រើប្រាស់នូវគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា១៣ .-**

វិញ្ញាបនបត្រហត្ថលេខាឌីជីថលដែលចេញដោយវិញ្ញាតធរហត្ថលេខាឌីជីថលបរទេស ត្រូវបានទទួលស្គាល់ស្របតាមលក្ខខណ្ឌនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដូចខាងក្រោម៖

ក- តាមការយល់ព្រមរបស់ **អ.ប.គ.** ឬ

ខ- តាមកិច្ចព្រមព្រៀងអន្តរជាតិទទួលស្គាល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៤
## អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល
## ផ្នែកទី១
## ការផ្តល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា១៤ .-**

គ្មានបុគ្គលណាអាចតាំងខ្លួនជាវិញ្ញាតជរហត្ថលេខាឌីជីថលបានទេ លុះត្រាតែបុគ្គលនោះបានទទួលអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលពី **អ.ប.គ.ព.** ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ឆ.** ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៥ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវមានជំនាញបច្ចេកទេស ធនធានហិរញ្ញវត្ថុ ប្រាក់តម្កល់ជានាអាជីវកម្ម គ្រឿងសម្ភារៈបរិក្ខារបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងគុណវុឌ្ឍិផ្សេងទៀតស្របតាមការកំណត់ដោយប្រកាសរបស់ **ក.ប.ឆ.**។

**មាត្រា១៦ .-**

អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលមានរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។

រយៈពេលនេះអាចត្រូវបានបន្តសាជាថ្មីតាមការសម្រេចរបស់ **អ.ប.គ.ព.** ក្រោយពីទទួលបានការឯកភាពពីរដ្ឋមន្ត្រី **ក.ប.ឆ.**។

**មាត្រា១៧ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវដាក់ពាក្យស្នើសុំមក **អ.ប.គ.ព.**។

លក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនិងការស្នើសុំបន្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **ក.ប.ឆ.**។

## ផ្នែកទី២
## ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា១៨ .-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវគោរពតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា១៩ .-**

ក្នុងករណីវិញ្ញាតជរហត្ថលេខាឌីជីថល មានបំណងចង់បញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល បុគ្គលនោះត្រូវ៖

ក- ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ **អ.ប.គ.ព.** យ៉ាងតិច ០៣ (បី) ខែ មុនថ្ងៃបញ្ឈប់ ដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ឈប់ និងចុះហត្ថលេខាដោយវិញ្ញាតជរហត្ថលេខាឌីជីថល

ខ- ជូនដំណឹងជាមុនដល់អ្នកប្រើប្រាស់សេវារបស់ខ្លួនយ៉ាងតិច ០៣ (បី) ខែ មុនថ្ងៃបញ្ឈប់

គ- ផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងកំណត់ត្រាវិញ្ញាបនបត្រហត្ថលេខាឌីជីថលទាំងអស់ដែលបានចេញ ទៅវិញ្ញាតធរហត្ថលេខាឌីជីថលផ្សេងមួយទៀត។

**គ.ប.ឌ.** ត្រូវកំណត់អំពីនីតិវិធីនៃការជូនដំណឹងអំពីការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល។

**មាត្រា២០ .-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល ត្រូវមានការយល់ព្រមជាមុនពី **អ.ប.គ.ព.** ស្របតាមការកំណត់របស់ **គ.ប.ឌ.** ។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **គ.ប.ឌ.**។

## ផ្នែកទី៣
## ការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា២១ .-**

អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូតក្នុងករណីណាមួយដូចខាងក្រោម៖

ក- វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ

ខ- វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវបានជម្រះបញ្ជីឬរំលាយក្រុមហ៊ុន

គ- វិញ្ញាតធរហត្ថលេខាឌីជីថលបានក្លែងបន្លំវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- សកម្មភាពរបស់វិញ្ញាតធរហត្ថលេខាឌីជីថលគំរាមដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ ឬការពារជាតិ

ង- ការផ្តល់ព័ត៌មានឬឯកសារក្លែងដោយវិញ្ញាតធរហត្ថលេខាឌីជីថលដល់ **អ.ប.គ.ព.**

ច- ការផ្ទេរកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការបញ្ឈប់វិញ្ញាតកម្មហត្ថលេខាឌីជីថល ដោយពុំគោរពតាមលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ឆ- ករណីផ្សេងទៀតដែលកំណត់ដោយ **គ.ប.ឌ.**។

សេចក្តីសម្រេចស្តីពីការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវផ្សាយជាសាធារណៈ។
នីតិវិធីនៃការដកហូតអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវកំណត់ដោយប្រកាសរបស់ **គ.ប.ឌ.**។

**មាត្រា២២ .-**

ក្នុងករណីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូត វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវជូនដំណឹងដល់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងត្រូវផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថលទៅវិញ្ញាតធរហត្ថលេខាឌីជីថលផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរបស់ **គ.ប.ឌ.**។

**គ.ប.ឌ.** ត្រូវកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីក្នុងការផ្ទេរវិញ្ញាបនបត្រហត្ថលេខាឌីជីថល ក្នុងករណីអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថលត្រូវបានដកហូត។

## ផ្នែកទី៤
## កម្រៃអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

**មាត្រា២៣ .-**

អ្នកស្នើសុំអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ឬវិញ្ញាតធរហត្ថលេខាឌីជីថល ត្រូវបង់កម្រៃនៃការស្នើសុំ កម្រៃអាជ្ញាបណ្ណ កម្រៃនៃការស្នើសុំបន្ត កម្រៃនៃការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ពាក់ព័ន្ធនឹងអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល និងកម្រៃផ្សេងទៀត ស្របតាមការកំណត់ដោយប្រកាសរួមរវាង **ក.ប.ឌ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## វិញ្ញាបនបត្រហត្ថលេខាឌីជីថល

**មាត្រា២៤ .-**

វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវរៀបចំវិធានរួមស្តីពីវិញ្ញាតកម្មហត្ថលេខាឌីជីថល ស្របតាមស្តង់ដានិងគោលការណ៍បច្ចេកទេសស្តីពីហត្ថលេខាឌីជីថល ដែលកំណត់ដោយប្រកាសរបស់ **ក.ប.ឌ.**។

**មាត្រា២៥ .-**

វិញ្ញាតធរហត្ថលេខាឌីជីថលត្រូវផ្តល់វិញ្ញាបនបត្រហត្ថលេខាឌីជីថលដល់បុគ្គលស្នើសុំ បន្ទាប់ពីបានបំពេញតាមលក្ខខណ្ឌ ដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

វិញ្ញាតធរហត្ថលេខាឌីជីថលអាចផ្អាក ឬបញ្ឈប់ការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល ស្របតាមការកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ក.ប.ឌ.** ត្រូវកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការផ្អាក និងការបញ្ឈប់ការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល។

**មាត្រា២៦ .-**

វិញ្ញាបនបត្រហត្ថលេខាឌីជីថលត្រូវកំណត់និទ្ទេសដូចខាងក្រោម៖

ក- អត្តសញ្ញាណរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ខ- គន្លឹះផ្ទៀងផ្ទាត់ហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

គ- ការពិពណ៌នាអំពីវិធីដែលប្រើប្រាស់ដើម្បីចុះហត្ថលេខាឌីជីថលលើវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- លេខសម្គាល់វិញ្ញាបនបត្រហត្ថលេខាឌីជីថល

ង- រយៈពេលសុពលភាពនៃវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ច- អត្តសញ្ញាណរបស់វិញ្ញាតធរហត្ថលេខាឌីជីថល

ឆ- វិសាលភាពនិងគោលបំណងនៃការប្រើប្រាស់វិញ្ញាបនបត្រហត្ថលេខាឌីជីថល

ជ- និទ្ទេសផ្សេងទៀតដែលកំណត់ដោយ **ក.ប.ឌ.**។

## ជំពូកទី៦
## ភារកិច្ចរបស់វិញ្ញាតធរហត្ថលេខាឌីជីថលនិងកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

**មាត្រា២៧ .-**

វិញ្ញាតធរហត្ថលេខាឌីជីថលមានភារកិច្ចដូចខាងក្រោម៖

ក- ការពារនិងរក្សាសន្តិសុខសុវត្ថិភាពពាក់ព័ន្ធនឹងការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល និងការប្រើប្រាស់ហត្ថលេខាឌីជីថលស្របតាមការកំណត់របស់ **អ.ប.ឌ.** និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ខ- មិនត្រូវរក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល លើកលែងតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរ

គ- មិនត្រូវប្រើប្រាស់ឬផ្សព្វផ្សាយគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឃ- រក្សាការសម្ងាត់ព័ត៌មានឯកជនរបស់កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ង- រក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលដោយសម្ងាត់និងមានសុវត្ថិភាព

ច- រក្សាទុកនិងគ្រប់គ្រងកំណត់ត្រានៃការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថលប្រកបដោយសុវត្ថិភាពក្នុងរយៈពេល ១០ ឆ្នាំ បន្ទាប់ពីផុតសុពលភាពនៃវិញ្ញាបនបត្រហត្ថលេខាឌីជីថល

ឆ- រាយការណ៍ភ្លាមទៅ **អ.ប.គ.ព.** ក្នុងករណីមានការអាក់រអួលនៃប្រព័ន្ធដំណើរការទិន្នន័យ ឬឧបករណ៍វិធីសាស្ត្រ និងប្រព័ន្ធវិញ្ញាតកម្ម ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង

ជ- ផ្តល់ជូនកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល នូវឧបករណ៍ ឬមធ្យោបាយដែលអនុញ្ញាតឱ្យជូនដំណឹងអំពីការលួច ការបាត់បង់ ឬការលាតត្រដាងនូវគន្លឹះបង្កើតហត្ថលេខាឌីជីថល

ឈ- ផ្តល់របាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានមិនមែនហិរញ្ញវត្ថុជាប្រចាំ ឬតាមការស្នើសុំរបស់ **អ.ប.គ.ព.**

ញ- ភារកិច្ចទាំងឡាយដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៨ .-**

កម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថលមានភារកិច្ចដូចខាងក្រោម៖

ក- រក្សាទុកគន្លឹះបង្កើតហត្ថលេខាឌីជីថលដោយសម្ងាត់និងមានសុវត្ថិភាព

ខ- ជូនដំណឹងទៅវិញ្ញាតធរហត្ថលេខាឌីជីថលជាបន្ទាន់និងទៅអ្នកទទួលទិន្នន័យដែលត្រូវបានផ្ញើនៅពេលដែលគន្លឹះបង្កើតហត្ថលេខាឌីជីថល ត្រូវបានលួច បាត់បង់ ឬលាតត្រដាង

គ- ភារកិច្ចទាំងឡាយដែលត្រូវបានកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី៧
## ការដោះស្រាយវិវាទ

**មាត្រា២៩ .-**

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ គ្រប់វិវាទដែលពាក់ព័ន្ធនឹងវិញ្ញាតធរហត្ថលេខាឌីជីថល ជាអាទិ៍ វិវាទរវាងវិញ្ញាតធរហត្ថលេខាឌីជីថលនិងវិញ្ញាតធរហត្ថលេខាឌីជីថល និងរវាងវិញ្ញាតធរហត្ថលេខាឌីជីថលនិងកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ភាគីវិវាទអាចដាក់សំណុំរឿងទៅ **អ.ប.ឌ.** ដើម្បីធ្វើការផ្សះផ្សា។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយប្រកាសរបស់ **អ.ប.ឌ.**។ កម្រៃសេវាសម្រាប់ដោះស្រាយវិវាទត្រូវកំណត់ដោយប្រកាសរួមរវាង **អ.ប.ឌ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៨
## ទោសប្បញ្ញត្តិ

**មាត្រា៣០ .-**

ក្រោយពេលផ្តល់អាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល ប្រសិនបើពិនិត្យឃើញថាវិញ្ញាតធរហត្ថលេខាឌីជីថល មិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **គ.ប.ឌ**. អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក- ដឹកនាំកែតម្រង់វិញ្ញាតធរហត្ថលេខាឌីជីថលឱ្យអនុវត្តតាមលក្ខខណ្ឌនិងលក្ខខណ្ឌបន្ថែម

ខ- ដាក់កំហិតលើអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល

គ- ព្យួរអាជ្ញាបណ្ណរហូតដល់វិញ្ញាតធរហត្ថលេខាឌីជីថលគោរពពេញលេញតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម។

ក្នុងករណីវិញ្ញាតធរហត្ថលេខាឌីជីថលមិនអនុវត្តតាមវិធានការ ដែលបានដាក់ចេញដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ឬបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **គ.ប.ឌ**. អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក- ព្យួរបណ្តោះអាសន្ន ឬបញ្ឈប់ការងាររបស់អគ្គនាយក នាយកប្រតិបត្តិ សមាជិកគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់របស់វិញ្ញាតធរហត្ថលេខាឌីជីថល

ខ- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់វិញ្ញាតធរហត្ថលេខាឌីជីថល។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ជូន **គ.ប.ឌ**. តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **គ.ប.ឌ**.

គ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់វិញ្ញាតធរហត្ថលេខាឌីជីថល ទោះបីជាសកម្មភាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណក៏ដោយ។

**គ.ប.ឌ**. អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២ លុះត្រាតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់វិញ្ញាតធរហត្ថលេខាឌីជីថល អំពីមូលហេតុនៃការចាត់វិធានការនេះនិងផ្តល់ឱកាសឱ្យវិញ្ញាតធរហត្ថលេខាឌីជីថលពន្យល់។

**មាត្រា៣១ .-**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ ដោយគ្មានអាជ្ញាបណ្ណពី **គ.ប.ឌ**. ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល។

**មាត្រា៣២ .-**

រាល់ការរក្សាទុកឬការប្រើប្រាស់នូវគន្លឹះបង្កើតហត្ថលេខាឌីជីថលរបស់អ្នកដទៃ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីកម្មសិទ្ធិករវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៧៥ ០០០ ០០០ (ចិតសិបប្រាំលាន) រៀល។

**មាត្រា៣៣ .—**

ការផ្សព្វផ្សាយនូវគន្លឹះបង្កើតហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ២៥ ០០០ ០០០ (ម្ភៃប្រាំលាន) រៀល ទៅ ៧៥ ០០០ ០០០ (ចិតសិបប្រាំលាន) រៀល។

**មាត្រា៣៤ .—**

វិញ្ញាតធរហត្ថលេខាឌីជីថលដែលបានផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ដោយពុំមានការយល់ព្រមជាមុនពី **អ.គ.ប.ព.** ស្របតាមការកំណត់របស់ **អ.ប.ឆ.** ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៥ .—**

រាល់វិញ្ញាតធរហត្ថលេខាឌីជីថលដែលមិនអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងមាត្រា២៧ ចំណុច (ឈ) នៃអនុក្រឹត្យនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា៣៦ .—**

រាល់ការរារាំង មិនសហការ ឬការបង្កជាឧបសគ្គដល់ការចុះត្រួតពិនិត្យការអនុវត្តអាជ្ញាបណ្ណវិញ្ញាតកម្មហត្ថលេខាឌីជីថល របស់មន្ត្រីដែលបានចាត់តាំងដោយ **អ.ប.ឆ.** ឬស្ថាប័នមានសមត្ថកិច្ចត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន)រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៣០ ០០០ ០០០ (សាមសិបលាន) រៀល។

**មាត្រា៣៧ .—**

រាល់វិញ្ញាតធរហត្ថលេខាឌីជីថលដែលមិនចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ឬយឺតយ៉ាវក្នុងការចេញវិញ្ញាបនបត្រហត្ថលេខាឌីជីថល ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ៣ ០០០ ០០០ (បីលាន) រៀល ទៅ ៩ ០០០ ០០០ (ប្រាំបួនលាន) រៀល។

**មាត្រា៣៨ .—**

ការដាក់ពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់ **អ.ប.ឆ.**។

**មាត្រា៣៩ .—**

បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចដែលមានចែងក្នុងមាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ និងមាត្រា៣៧ នៃអនុក្រឹត្យនេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចពិន័យ។

ក្នុងករណីជនល្មើសមិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមការកំណត់ដូចកថាខណ្ឌទី១ ខាងលើ **អ.ប.ឆ.** ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅអយ្យការអមសាលាដំបូង។

ទម្រង់បែបបទនៃការពិន័យនិងការគ្រប់គ្រងប្រាក់ ដែលបានមកពីការពិន័យត្រូវកំណត់ដោយប្រកាសរួមរវាង **អ.ប.ឆ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា៤០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣រោច ខែមិគសិរ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ